រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ : ១៣៦ស...ជ.អ.ក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស

## ស្ដីពី

## ការតែងតាំងមុខតំណែង ប្រគល់ភារកិច្ច និងផ្លាស់ប្ដូរកន្លែងធ្វើការជាជូនមន្ត្រីរាជការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/០៦/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ និងមាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួន នៃអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានតែងតាំងលោក **សួង ថុន** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ជាអនុប្រធានការិយាល័យត្រួតពិនិត្យ និងវាយតម្លៃ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ២** : ត្រូវបានប្រគល់ភារកិច្ចលោក **អ៊ុក សុត្ថា** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៣ ជាអនុប្រធានការិយាល័យត្រួតពិនិត្យនិងវាយតម្លៃ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ៣** : ត្រូវបានផ្ទេរ លោក **មុត វ៉ាយ** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៤ មកជាមន្ត្រីនៅក្នុងការិយាល័យហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ នៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ៤** : លេខាធិការដ្ឋាន គ.ជ.អ.ប អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភា និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ប្រការ២ និងប្រការ៣ ខាងលើត្រូវទទួលអនុវត្តតាមប្រកាសនេះ។

**ប្រការ ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

ស ខេង

**<u>កន្លែងទទួល</u>** ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ